# សភាអឺរ៉ុប គាំទ្រកំណែទម្រង់ទីផ្សារកាបូន



សម័យប្រជុំរបស់សភាអឺរ៉ុប

XINHUANET ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

កាលពីថ្ងៃពុធ ទី២២ ខែមិថុនា ឆ្នាំ២០២២ សមាជិកសភាអឺរ៉ុប (MEPs) បានបោះឆ្នោតលើសេចក្តីព្រាងច្បាប់សំខាន់ៗចំនួន៣ ក្នុងគោលបំណងជំរុញឱ្យមានសកម្មភាពអាកាសធាតុ និងឯករាជ្យភាពថាមពលរបស់សហភាពអឺរ៉ុប (EU) កាន់តែលឿនជាងមុន។

សមាជិកសភាអឺរ៉ុបបានមានប្រសាសន៍ថា ប្រព័ន្ធជួញដូរការបំភាយឧស្ម័ន(ETS)គួរតែត្រូវបានធ្វើកំណែទម្រង់ ហើយវិសាលភាពរបស់វាកាន់តែធំឡើង ដើម្បីលើកទឹកចិត្តដល់ឧស្សាហកម្មនានាឱ្យកាត់បន្ថយការបំភាយឧស្ម័នរបស់ពួកគេបន្ថែមទៀត និងវិនិយោគលើបច្ចេកវិទ្យាកាបូន។ សមាជិកសភាអឺរ៉ុបក៏បានអំពាវនាវឱ្យមានវិសាលភាពទូលំទូលាយ និងការអនុវត្តលឿនជាងមុននៃយន្តការកែតម្រូវព្រំដែនកាបូនរបស់សហភាពអឺរ៉ុប(CBAM)។ លោក Pascal Canfin ប្រធានគណៈកម្មាធិការបរិស្ថាននៃសភាអឺរ៉ុបបានមានប្រសាសន៍ថា កំណែទម្រង់ទីផ្សារកាបូន និងមូលនិធិអាកាសធាតុសង្គម គឺជាជំហានដ៏ធំមួយឆ្ពោះទៅមុខសម្រាប់សកម្មភាពអាកាសធាតុ។ សមាជិកសភាអឺរ៉ុបជឿថា ETS បានបង្កឱ្យមានការថយចុះយ៉ាងខ្លាំងនៃការបំភាយឧស្ម័នរួចហើយ។ យោងតាមសេចក្តីព្រាងច្បាប់នេះ ប្រាក់ឧបត្ថម្ភឥតគិតថ្លៃនៅក្នុងវិស័យ ETS ដែលគ្របដណ្តប់ដោយយន្តការកែតម្រូវព្រំដែនកាបូន(CBAM) គួរតែត្រូវបានលុបចោលបន្តិចម្តងៗចាប់ពីឆ្នាំ២០២៧ ហើយនឹងបាត់ទៅវិញទាំងស្រុងនៅឆ្នាំ២០៣២ នៅពេលដែលសភាចង់ឱ្យយន្តការនេះត្រូវបានអនុវត្តន៍ពេញលេញ។ សមាជិកសភាអឺរ៉ុបក៏បានបង្កើតមូលនិធិអាកាសធាតុសង្គមដែលមានគោលបំណងការពារគ្រួសារ និងអាជីវកម្មដែលងាយរងគ្រោះបំផុតពីភាពក្រីក្រថាមពល។

ច្បាប់សំខាន់ៗទាំង៣ខាងលើនេះ គឺសំដៅទៅលើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់យ៉ាងតិច ៥៥% នៅឆ្នាំ២០៣០ បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩០ និងសម្រេចឱ្យបាននូវការបំភាយឧស្ម័នផ្ទះកញ្ចក់កម្រិតសូន្យនៅឆ្នាំ២០៥០ អនុលោមតាមច្បាប់អាកាសធាតុអឺរ៉ុប។ សភាអឺរ៉ុបនឹងចាប់ផ្តើមការចរចាជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសក្នុងសហភាពអឺរ៉ុបលើទម្រង់ចុងក្រោយនៃច្បាប់ទាំងនេះ ៕

*ព័ត៌មានសភាអន្តរជាតិ ២៤-០៦-២២-ផាត់ ត្រដែត*

ប្រែសម្រួលពីៈ https://english.news.cn/europe/20220623/8d78f99281e14c8bbdc0a4512efca6da/c.html

# European Parliament backs carbon market reforms

*Source: Xinhua| 2022-06-23 02:28:44|Editor: huaxia*

BRUSSELS, June 22 (Xinhua) -- Members of the European Parliament (MEPs) voted in three major draft laws aimed at pushing for faster European Union (EU) climate action and energy independence on Wednesday.

MEPs said the Emissions Trading System (ETS) should be reformed and its scope enlarged, in order to encourage industries to further reduce their emissions and invest in low-carbon technologies.

They also called for a broader scope and faster implementation of the EU Carbon Border Adjustment Mechanism (CBAM).

Pascal Canfin, Chair of the Environment Committee at the European Parliament, tweeted that the reform of the carbon market and social climate fund are big steps forward for climate action.

MEPs believe that the ETS has already triggered significant reductions in emissions.

According to the draft laws, the free allowances in the ETS sectors covered by the Carbon Border Adjustment Mechanism (CBAM) should be phased out from 2027, and completely disappear by 2032 when Parliament wants the mechanism to be fully implemented.

MEPs also developed the Social Climate Fund, which aims at protecting the households and businesses most vulnerable to energy poverty.

The three key EU laws are part of the "Fit for 55 in 2030 package." This is aimed at cutting greenhouse gas emissions by at least 55 percent by 2030 compared to 1990 levels, and achieving net-zero greenhouse gas emissions by 2050, in line with the European Climate Law.

The European Parliament will begin negotiations with EU governments on the final shape of these laws. ■